# ការសម្ភាសរបស់អ៊ុំស្រី ខួន សារឿន

**កៈ អ្នកសម្ភាស ឡេង ឆាវី　　　　ខៈ អ្នកត្រូវគេសម្ភាស ខួន សារឿន**

កៈ អូខេ អញ្ចឹងជាដំបូងសូមអរគុណអ៊ុំថ្ងៃហ្នឹងដែលបានឱ្យខ្ញុំមកសម្ភាសនៅហ្នឹង ហើយពួកខ្ញុំធ្វើការសម្ភាសនៅថ្ងៃទី០៣ខែកញ្ញាឆ្នាំ២០១៩ ហើយពួកខ្ញុំធ្វើការសម្ភាសហ្នឹងគឺនៅអី...អ៊ុំជួយប្រាប់នៅហ្នឹងអី... ឈ្មោះភូមិឃុំអីដែរ?

ខៈ នៅភូមិបឹងស្នាយ។

កៈ ឃុំ?

ខៈ ឃុំបឹងស្នាយ ខេត្តកំពង់ចាម។

កៈ អញ្ចឹងជាដំបូងខ្ញុំសុំសួរអ៊ុំមានឈ្មោះអីដែលអ៊ុំ?

ខៈ អ៊ុំឈ្មោះខួន សារឿន។

កៈ អញ្ចឹងអ៊ុំតាំងពីតូចមកមានឈ្មោះគេហៅក្រៅអីទៀតអត់អ៊ុំ?

ខៈ ហៅក្រៅឈ្មោះអ៊ុំសា រីន។

កៈ អ៊ុំសា រីន?

ខៈ ចាសឈ្មោះបញ្ជីជាតិឈ្មោះអ៊ុំសា រឿន។

កៈ អញ្ចឹងសព្វថ្ងៃអ៊ុំមានអាយុប៉ុន្មានដែលអ៊ុំ?

ខៈ អ៊ុំអាយុហុកសិបឆ្នាំ។

កៈ ហុកសិបឆ្នាំ?ហើយអ៊ុំចាំថ្ងៃខែឆ្នាំកំណើតខ្លួនឯងអត់អ៊ុំកើតនៅថ្ងៃណា?

ខៈ អ៊ុំកើតថ្ងៃអត់ដឹងទេប៉ុន្តែអ៊ុំកើតនៅឆ្នាំមួយពាន់ប្រាំបួនរយហាសិបប្រាំបួន។

ខៈ អញ្ចឹងដល់ពេលស្រុកកំណើតអ៊ុំនៅខាងណាវិញអ៊ុំ?

ខៈ ស្រុកកំណើតអ៊ុំនៅស្រុកបាធាយ ស្រុកបាធាយខេត្តកំពង់ចាម។

កៈ ដល់ពេលមានគ្រួសារបានផ្លាស់មកនៅកំពង់ចាមហ្នឹងមែនអ៊ុំ?

ខៈ អ៊ុំមកនៅហ្នឹងទើបមកនៅទើបបានដប់ប្រាំបី ដប់ប្រាំបួនឆ្នាំនេះហ្នឹងតែពីសង្គមចាស់អ៊ុំនៅកំពង់ចាមហ្មងផ្ទះអ៊ុំខាងជើងត្បូងស្ពានគីហ្សូណាអាហ្នឹងពីមុនហាស។

កៈ ចាស!

ខៈ រួចទៅគេជំលៀសអ៊ុំពីកំពង់ចាមហ្នឹងទៅៗនៅស្រុកបាធាយស្រុកជីដូនជីតានៅស្រុក

បាធាយ។

កៈ ចាស!

ខៈ ហ្នឹងហ៎!ហើយអ៊ុំទៅនៅស្រុកបាធាយហ្នឹងរហូតទាល់តែពេលចូលតំបន់ខ្មែរក្រហមរហូតទាល់តែដាច់ប៉ុលពតហ្នឹងទៀតមកជំនាន់ចិតសិបប្រាំបួនអ៊ុំនៅហ្នឹងនៅបាធាយដដែល អ៊ុំទើបមកឆ្នាំ២០០៣នេះបានអ៊ុំមកនៅកំពង់ចាមវិញ។

កៈ ចាស!

ខៈ អ៊ុំមកនៅកំពង់ចាមបានអ៊ុំមកចូលក្នុងសាសនាហ្នឹងហាសបន្ទាប់មកអ៊ុំចូលរហូតហ្មង។

កៈ អញ្ចឹងចង់សួរអ៊ុំមានបងប្អូនប៉ុន្មាននាក់ដែលអ៊ុំ?

ខៈ អឺ...បងប្អូនអ៊ុំច្រើនហាសបងប្អូនបង្កើតអ៊ុំមាន៨នាក់ តែគេយកទៅសម្លាប់ជំនាន់ប៉ុល

ពតអស់៤គ្រួសារសរុបទាំងបងថ្លៃទាំងបងបង្កើតហើយទាំងឪពុកមួយទៀតទាំងក្មួយដប់ប្រាំមួយនាក់ទៀតវាស្មើម្ភៃប្រាំនាក់។

កៈ ដល់ពេលអញ្ចឹងបងប្អូនដែលគាត់ស្លាប់អស់បួននាក់ហ្នឹងកាលគាត់ស្លាប់គាត់អាយុប៉ុន្មានដែលអ៊ុំ?

ខៈ មិនដឹងគាត់អាយុប៉ុន្មានទេគាត់ប្រហែលជាហាជាងហុកអីទៅហើយយ៉ាងបើគាត់អាយុ

ច្រើនៗដែលហ្នឹង។

កៈ ចាស!

ខៈ អ៊ុំមិនដឹងឆ្នាំទេតែបើបូននឹងឆ្នាំឥឡូវវាចូលប៉ែតជាងហើយ បងទីមួយប្រហែលជាខ្ទង់

ប៉ែតប្រាំ ប៉ែតប្រាំមួយហើយបងទីពីរប្រហែលប៉ែតគត់ បងទីបីប្រហែលជាចិតសិបប្រាំបួន បងទីបួននៅនេះប្រហែលជាចិតសិបប្រាំ អញ្ចឹងបងដែលទៅហ្នឹងប្រហែលជាចិតសិបបី។

ក៖ អញ្ចឹងអឺ...គាត់ស្លាប់ហ្នឹងគឺប៉ុលពតគាត់យកទៅសម្លាប់ចោល?

ខ៖ ប៉ុលពតយកមកសម្លាប់ចោលហ្មងមួយគ្រួសារហ្នឹងមួយឡានល្មម ហើយអ៊ុំកាលណុងបានជានៅបងប្អូនបួននាក់តែបងប្អូនអ៊ុំបែកគ្នាខ្លះ ខ្លះទៅគេយកមកធ្វើចល័តនៅឯភ្នំជីទៅបងប្រុសមួយទៀតរត់ទៅនៅស្រុកគេឆ្ងាយហើយបងស្រីមួយទៀតរត់មកនៅចម្ការលើទៅអ៊ុំនៅតែពីរនាក់ម៉ែកូនជំនាន់ប៉ុលពតហើយអ៊ុំកាលនោះអាយុក៏មិនមែនច្រើនដែលអាយុដប់ឆ្នាំជាងហ្នឹងដប់បួនឆ្នាំអី។

ក៖ ហើយអញ្ចឹងអ៊ុំជាកូនទីប៉ុន្មានដែលអ៊ុំ?

ខ៖ អ៊ុំពៅគេបង្អស់។

ក៖ អូ...កូនពៅ?

ខ៖ ហ្នឹងហើអ៊ុំកូនពៅគេ។

ក៖ អញ្ចឹងអ៊ុំអាចរៀបរាប់ឈ្មោះប្អូនតាំងពីបងទីមួយរហូតមកដល់អ៊ុំ?

ខ៖ អ៊ុំរៀបរាប់បាន បងទីមួយប្ដីគាត់ឈ្មោះជុំ ចាន់ ប្រពន្ធឈ្មោះឡោ យន។

ក៖ ចាស!

ខ៖ បងទីពីរប្ដីឈ្មោះឡី លីម ប្រពន្ធ ខួន ខែម បងទីបីប្ដីគាត់ឈ្មោះដួវ ងារ ប្រពន្ធគាត់ឈ្មោះ

ខួន ឃីម។

ក៖ ចាស!

ខ៖ បងទីបួនប្ដីគាត់ឈ្មោះនីត សារឿន ប្រពន្ធគាត់ឈ្មោះខួន ឃាន ទាំងអស់ទាំងប្ដីទាំងប្រពន្ធវាប្រាំបីនាក់ហើយណាស់។

ក៖ ហើយចុះដល់ពេលកូនទីប្រាំ?

ខ៖ ហើយឪពុកអ៊ុំមួយទៀតព្រមទាំងឪពុកអ៊ុំមួយទៀត ឪពុកអ៊ុំឈ្មោះខួន ឡោជាឪពុក។

ក៖ ចាស!

ខ៖ រាប់ហ្នឹងអស់ហើយនៅតែក្មួយៗទេ ក្មួយទីមួយ...។

ក៖ អញ្ចេះមិញអ៊ុំថាបងប្អូនប្រាំបីនាក់ហីអ៊ុំ អញ្ចឹងអ៊ុំរៀបរាប់ឈ្មោះបានតែប្រាំ។

ខ៖ នេះអ៊ុំរៀបរាប់បានតែអ្នកស្លាប់ទេណាស់។

ក៖ អត់ទេចង់ឱ្យរៀបរាប់បងប្អូនទាំងអស់ហ្មងហាស។

ខ៖ បងប្អូនទាំងអស់?

ក៖ ចាសបងប្អូនទាំងអស់ហាស។

ខ៖ បងប្អូនបង្កើតអ៊ុំទី១ ខួន យន ទី២ខួន ខែម ទី៣ខួន ឃីម ទី៤ខួន ឃាន ទីប្រាំខួន លាង ប្រាំមួយខួន ឡា ទី៧ខួន សារុននោះនៅសៀមរាប ទី៨អ៊ុំហ្នឹងខួន សារឿន។

ក៖ ហើយអញ្ចឹងចង់សួរអ៊ុំដែលថាតាំងពីតូចមកអ៊ុំមានការចងចាំអ្វីខ្លះជាមួយបងប្អូនអ៊ុំហាស ដូចមានអនុស្សាវរីយអ្វីជាមួយគ្នាខ្លះអ៊ុំ?

ខ៖ អ៊ុំមានចងចាំតែកាលជំនាន់ប៉ុលពតហ្នឹងអ៊ុំធំកាលជំនាន់ប៉ុលពតហ្នឹងវាកំសត់ហួសពីការកំសត់ហើយនៅជាមួយបងប្អូនច្រូតកាត់នៅហ្នឹងអ៊ុំទៅឃ្វាលគោទៅត្រលប់មកវិញគេយកបងប្អូនទៅសម្លាប់ចោលហើយរស់នៅតែពីរនាក់ម៉ែកូនហ្នឹង ជំនាន់ប៉ុលពតអ៊ុំសន្លប់តាំងពីម៉ោង៧ល្ងាចទល់ម៉ោង៧ព្រឹកបានអ៊ុំដឹងខ្លួន?

ក៖ ពេលណុងថីបានសន្លប់អ៊ុំ?

ខ៖ បើអត់មានបាយញ៉ាំផង។

ក៖ អូ...

ខ៖ អ៊ុំហូបដំឡូងតែមួយដុំរួចទៅអាដំឡូងមួយដុំហ្នឹងអត់ហ៊ានហូបខ្លួនឯងទុកឱ្យម្ដាយដល់

អញ្ចឹងអ៊ុំអត់មានហូបអីទាំងអស់អ៊ុំហូបតែទឹកទទេទឹកអញ្ចឹងទៅហើយជួនកាលដើមច្រាចយើងហ្នឹងទំពារលេបៗទៅ រាល់តែថ្ងៃជួនកាលបានហូបជួនកាលអត់ស្រុកអ៊ុំហ្នឹងតឹងហាសតឹងមែនទែនហ្មងជំនាន់ប៉ុលពតហាសដំឡូងមួយដុំប៉ុននេះទេប្រហែលប្រវែងហ្នឹងគេឱ្យតែមួយដុំហ្នឹងទេ។

ក៖ ចាស!

ខ៖ អញ្ចឹងលៃឱ្យម្ដាយទៅខ្លួនឯងសន្លប់។

ក៖ អូ...

ខ៖ រួចពីហ្នឹងមកទៅមកដល់ឆ្នាំ៧៩នេះបានអ៊ុំធូរធារបន្តិចមិនធូរអីណាស់ណាទេធូរគ្រាន់ថាបងប្អូនមកជុំគ្នាមានបងមានប្អូនទៅណាស់ នៅសល់បងប្អូនបួននាក់រាល់ថ្ងៃហ្នឹងអ៊ុំនៅសល់បងស្រីមួយហើយនឹងអ៊ុំមួយទៀតវាស្រីពីរប្រុសពីរតែបងប្រុសអ៊ុំបួសទៅជាលោកសង្ឃហើយឥឡូវគាត់បួសហើយ។

ក៖ ចាស!

ខ៖ គាត់អាយុច្រើនហើយគាត់ជិត៨០ហើយហ្នឹង។

ក៖ ចាស!

ខ៖ ហើយអ៊ុំចេះតែរកទៅរហូតទាល់តែដាច់ឆ្នាំប្រហែលជា៨៩ហ្នឹងចុង៨៩ហ្នឹងអ៊ុំបានអាយុដប់ប្រាំមួយឆ្នាំអ៊ុំការ។

ក៖ អូ...

ខ៖ ហ្នឹងហើអ៊ុំការទៅក៏ចេះតែរកស៊ីរហូតទល់មកដល់ឆ្នាំ២០០២ ២០០៣ហ្នឹងដកស៊ីគាត់មកពីអាមេរិកគាត់និយាយពីក្ដីជំនឿអីៗទៅក៏អ៊ុំទុកផ្ទះចោលមកនៅនេះលក់ផ្ទះលក់អីអស់ទៅយកលុយសងគេអស់អ៊ុំមកនេះអ៊ុំចូលនៅហ្នឹងរហូតទល់សព្វថ្ងៃហ្នឹង។

ក៖ ចាស!

ខ៖ ហើយអ៊ុំបាតដៃទទេមកដល់នេះគ្មានទេកូនអើយរកតែបាយហូបមិនបានទេបើលក់ផ្ទះហ្នឹងបានលុយ៣០០០ជាងហ្នឹងគ្រាន់តែសងគេមិនគ្រប់ផងជំពាក់គេនោះ ជំពាក់គេច្រើនយើងចេះតែខ្ចីគេណាមួយម្ដាយចាស់ ម្ដាយទាំងសងខាងទាំងម្ដាយក្មេកទាំងម្ដាយបង្កើតទៅអត់មានអីមើលគាត់អញ្ចឹងចេះតែខ្ចីលុយគេចងការគេអញ្ចឹងខ្ចីខាងនេះទៅយកមកព្យាបាលគាត់បន្តិចខាងនោះទៅយូរៗបំណុលកាន់តែកើនហាស។

ក៖ ចាស!

ខ៖ ហ្នឹងហើដល់ពេលកាន់តែកើនអ៊ុំលក់ផ្ទះនៅនោះសងគេអស់ទៅអ៊ុំមកនេះបាតដៃទទេមានតែលុយ៨០០០ធ្វើសោហ៊ុយអស់សល់លុយប្រាំពាន់។

ក៖ចាស!

ខ៖ មិនមែន៨០០០ដុល្លារទេណាស់៨០០០លុយខ្មែរ រួចទៅអ៊ុំក៏នៅហ្នឹងទៅហើយអ៊ុំមិនដែលគិតអីទេដឹងតែថាពេលថ្ងៃអាទិត្យទៅព្រះវិហារៗលែងខ្វល់ពីរឿងទ្រព្យសម្បិត្តអីទៀតបើវាអស់ហើយអស់រលីងហើយអត់មានអីផង។

ក៖ ចាស!

ខ៖ យើងចេះតែទៅរហូតទល់ឥឡូវហ្នឹងបានទ្រង់ផ្តល់ពរជ័យទៅក៏អ៊ុំបានមានផ្ទះអញ្ចឹងបានអ៊ុំនៅតែមានសេចក្តីជំនឿមិនថយទេព្រោះទ្រង់ផ្តល់ឱ្យអ៊ុំបានច្រើន។

ក៖ ហើយមួយទៀតចង់សួរកាលនៅពីក្មេងអ៊ុំចូលចិត្តលេងអីឬក៏ធ្វើអីខ្លះជាមួយបងប្អូនកាលនៅពីក្មេងហាអ៊ុំ?

ខ៖ បងប្អូនអ៊ុំគាត់ធំៗទៅដូចថាអ៊ុំដឹងក្តីមកបងប្អូនគាត់ធំៗទៅនៅតែបងស្រីហ្នឹងលេងតែពីរនាក់បងប្អូនហ្នឹងលេងតែឡុកឡហ្នឹងគ្មានស្អីទេពីនាក់បងប្អូនលេងតែឡុកឡទល់ៗល្ងាចរួចពីហ្នឹងទៅឃ្វាលគោរួចត្រឡប់មកវិញលេងទៀតហ៊ីហើយអ៊ុំអត់ចេះទាស់គ្នាទេពីរនាក់បងប្អូនហ្នឹងបើគេស្លាប់អស់ហើយនៅតែពីរនាក់បងប្អូនស្រីៗហ្នឹងតែឥឡូវក្មួយស្គាល់ទេម៉ាក់អ៊ែលឌើរ

រ័ត្នានោះ?

ក៖ អឺ...អត់ផង។

ខ៖ គាត់ឥឡូវនៅសៀមរាបឥឡូវទ្រង់ផ្តល់ពរជ័យគាត់ក៏គ្រាន់បើដែល។

ក៖ ហើយអញ្ចឹងចង់សួរបងប្អូនអ៊ុំដែលនៅរស់ទាំងបួននាក់ហ្នឹងឥឡូវគាត់នៅខេត្តណាខ្លះ?

ខ៖ គាត់នៅខេត្តកំពង់ចាមទាំងអស់។

ក៖ គាត់នៅកំពង់ចាមទាំងអស់ទាំងបួននាក់មែនអ៊ុំ?

ខ៖ បួននាក់ តែគ្រាន់ថាបងទីមួយឥឡូវហ្នឹងបងហ្នឹងទៅជាទីមួយវិញហាសបងទី៤ហ្នឹងវាទៅជាទី១វិញហើយ បងទី១គាត់បួសចាលោកសង្ឃ។

ក៖ ចាស!

ខ៖ ហ្នឹងហើយៗទី២គាត់រទេ្រតហើយនៅទល់ខ្នងគ្នាផ្ទះខាងនេះ។

កៈ ចាស!

ខៈ ហើយបងទី៣នៅសៀមរាបម្តាយស៊ីស្មើរ័ត្នហ្នឹង។

ខៈ ហ្នឹងហើយ រូចទី៤អ៊ុំហ្នឹងហ្មង។

កៈ ចាសហើយមួយទៀតចង់សួរអ៊ុំពីឪពុកម្តាយៗអ៊ុំឈ្មោះអីដែល?

ខៈ ឪពុកអ៊ុំឈ្មោះខួន ឡេា ម្តាយអ៊ុំឈ្មោះម៉ូវ ចាន់។

កៈ ហើយអញ្ចឹងអឺ...ឪពុកអ៊ុំគាត់នៅរស់ដល់សព្វថ្ងៃឬក៏...?

ខៈ គាត់ស្លាប់ជំនាន់ប៉ុលពតបាត់ហើយគាត់ស្លាប់មុនប៉ុលពតទៀត។

កៈ ដល់ពេលគាត់ស្លាប់គាត់អាយុប៉ុន្មានអ៊ុំចាំអត់?

ខៈ គាត់ស្លាប់ហ្នឹងអាយុប្រហែលជា៧០ អីហើយមើលទៅបើមិនអញ្ចឹងហុកជាងអីហ្នឹងព្រោះកាលនោះគេចាប់ខ្លួនគាត់យកទៅសម្លាប់អ៊ុំអត់ដឹងផងកាលណុងគេមកចាប់ខ្លួនគាត់នៅឆ្នាំ៧០គត់ទម្លាក់គ្រាប់បែកហ្នឹងគេទម្លាក់គ្រាប់បែកនៅភូមិជើងព្រៃហ្នឹងទម្លាក់ទៅអ៊ុំនៅតែម្នាក់ឯងនៅក្នុងផ្ទះហ្នឹងហើយទៅម្តាយអីទៅច្រូតអស់ទៅឪពុកគាត់រត់មិនដឹងរត់ពីត្រឹមណាមកទេបែបមកពីកំពង់ចាមមើលទៅហើយកាត់រត់ទៅយកអ៊ុំនៅក្នុងភ្លើងកំពុងតែឆេះហ្នឹងហើយអ៊ុំអត់មានអាវទេមានតែខោលីអូមួយហ្នឹងបើអ៊ុំតូចមួយអាយុប្រហែលជា៤ឆ្នាំជាងហ្នឹងអត់ទាន់បានប្រាំឆ្នាំផងហ្នឹងហើយទៅឪពុករត់ទៅអោបអ៊ុំយកទៅៗរហូតទៅភូមិគេហៅភ្នំវិហារ ទៅដល់ភ្នំវិហារហ្នឹងក៏ឪពុកក៏ដេកលើឃឿនវិហារលោកហ្នឹងទៅហើយគាត់ដេកទៅដាក់អ៊ុំពីលើទ្រូងៗទៅពេលអ៊ុំដឹងខ្លួនគេចាប់ឪពុកបាត់អ៊ុំអត់ដឹងរហូតទល់សព្វថ្ងៃ។

កៈ ចាស!

ខៈ អ៊ុំក្រាបនៅលើទ្រូងគាត់អ៊ុំដេកលក់ហើយណាស់ហើយទៅក៏ព្រាត់។

កៈ អញ្ចឹងអត់មានអ្នកណាដឹងថាគាត់គេចាប់ឬក៏ម៉េច?

ខៈ ដឹងថាគេចាប់ឪពុកហើយតែអ៊ុំក្រោកឡើងដឹងតែស្រែករកឪពុកហាស។

កៈ ចាស!

ខ៖ អ៊ុំស្រែករកឪពុកអ៊ុំថាពុកទៅណាអ៊ុំស្រែករកឪពុកព្រោះអ៊ុំអត់ដែលបែកពីឪពុកអ៊ុំទេទៅណាក៏ឪពុកពរអ៊ុំទៅដែរទោះបីគាត់ទៅខេត្តណាក៏គាត់អត់ដែលទុកអ៊ុំចោលដែរ ដល់ពេលអ៊ុំដឹងខ្លួនឡើងបាត់ឪពុកអ៊ុំស្រែករកហើយម្ដាយអ៊ុំសន្លប់។

ក៖ ចាស!

ខ៖ គាត់ស្រែកយំថាកូនកុំយំពុកគេចាប់ខ្លួនបាត់ហើយកុំយំកូនប្រឹងប្រែងទៅរួចពីហ្នឹងទៅអ៊ុំដើរតាំងពីភ្នំវិហារហ្នឹងរហូតមកជិះឡានមកកំពង់ចាមវិញនៅឆ្នាំ៧០គត់ដល់ត្រឹមកន្លែង៨៨កាលហ្នឹងគេដេញបាញ់ទាំងឡានហ្នឹងម្ដងទៀត តែម្ដាយអ៊ុំគាត់ថាក្រាបកូនក្រាបឡានកុំឈប់បើកទៅងាប់ត្រឹមណាចោលត្រឹមហ្នឹងក៏មកដល់កំពង់ចាមរួចគេជំលៀសពីកំពង់ចាមទៅវិញ

ដដែល។

ខ៖ អ៊ុំព្រាឪពុកអញ្ចឹងអ៊ុំមិនចង់និយាយពីរឿងឪពុកអ៊ុំទេ អ៊ុំអត់បានប្រាំឆ្នាំទេកូនអ៊ុំស្គាល់ឪពុកអ៊ុំស្គាល់តិចណាស់ អ៊ុំចាំថាពេលដែលដេកទៅគាត់សួរថាមីតូចកូងឯងឃ្លានអី ខ្ញុំអត់ឃ្លានអីផងពុករួចទៅអ៊ុំចាក់ច្រមុះគាត់ចាក់ភ្នែកគាត់ហើយគាត់ថាមីតូចលេងតែចាក់ភ្នែកពុកអញ្ចឹងកូនកុំចាក់មើលកូនឯងរពឹសម៉េសប្រយ័ត្នពុកវៃហាសទៅក៏ខឹងអ៊ុំចិត្តច្រើនអ៊ុំខឹងអ៊ុំក្រាបតោងកគាត់ក៏ដេកលក់តាំងពីហ្នឹងមកបាត់ឪពុកទល់រាល់ថ្ងៃ។

ក៖ អញ្ចឹងដល់ពេលម្ដាយអ៊ុំគាត់អាយុប៉ុន្មានដែរគាត់នៅរស់ដល់ឥឡូវ?

ខ៖ គាត់ស្លាប់បាត់ហើយបើនៅដល់សព្វថ្ងៃហ្នឹងអាយុគាត់ជាង១០០ហើយម្ដាយអ៊ុំ។

ក៖ ចាស!

ខ៖ បើគ្រាន់តែអ៊ុំពៅគេផងអាយុហុកសិបហើយហ្នឹង។

ក៖ អញ្ចឹងកាលគាត់ស្លាប់ហ្នឹងគាត់ស្លាប់អាយុប៉ុន្មានអ៊ុំ?

ខ៖ គាត់ស្លាប់កាលនៅអាយុ៨១។

ក៖ គាត់អាយុ៨១អ៊ុំ?

ខ៖ ហ្នឹងហើយគាត់ស្លាប់៨១។

ក៖ អញ្ចឹងអឺ...គាត់ស្លាប់នៅឆ្នាំណាអ៊ុំចាំអត់?

ខ៖ គាត់ស្លាប់នៅឆ្នាំ៩៧។

កៈ ឆ្នាំ១៩៩៧មែនអ៊ុំ?

ខៈ ហ្នឹងហើយ៩៧នេះ។

កៈ ហើយដល់ពេលអញ្ចឹងអ៊ុំអាចដឹងអត់ថាឪពុកអ៊ុំគាត់មានស្រុកកំណើតនៅស្រុកណា?

ខៈ ស្រុកកំណើតនៅជាមួយគ្នាស្រុកតែមួយស្រុកបាធាយហ្នឹងទាំងអស់។

កៈ ចុះម្ដាយវិញ?

ខៈ ម្ដាយក៏ស្រុកបាធាយ។

កៈ ហើយដល់ពេលអញ្ចឹងចង់ឱ្យអ៊ុំនិយាយរៀបរាប់ពីឪពុកអ៊ុំថាគាត់ជាមនុស្សបែបណាជាមនុស្សកាចឬក៏ជាមនុស្សស្លូត?

ខៈ គាត់ស្លូតណាស់ស្លូតហើយគាត់ស្គាល់ខុសស្គាល់ត្រូវគាត់មនុស្សរបៀបបុរាណតាំងពីជំនាន់ជ័យវរ្ម័នហើយកម្ពស់គាត់ខ្ពស់ណាស់គាត់ខ្មែរក៏ពិតមែនតែច្រមុះគាត់ក្ដោងហើយគាត់កម្ពស់ពីរម៉ែត្រពីតឹកកម្ពស់គាត់។

កៈ អូ...ខ្ពស់ហាសណ៎។

ខៈ កម្ពស់គាត់នៅប្រទេសកម្ពុជាមានតែលោកទីហ្គោលទេដែលលើសគាត់ពីរតឹកគឺគាត់ខ្ពស់ជាងគេទាំងអស់។

កៈ អូ...ខ្ពស់ហា។

ខៈ បើអ៊ុំនិយាយថាឪពុកខ្ពស់ហើយអ៊ុំទាបអញ្ចឹងគេអត់ជឿទេឆ្ងាយពីគ្នាណាស់អ៊ុំពីរតបានស្មើគាត់។

កៈ អញ្ចឹងប្រហែលអ៊ុំកាត់ទៅខាងម្ដាយទេដឹងអ៊ុំ?

ខៈ អត់ទេម្ដាយអ៊ុំក៏ខ្ពស់ដែរ តែកាត់ទៅម្ដាយមីងខាងប្អូនម្ដាយរបស់អ៊ុំ។

កៈ អូ...

ខៈ បើបងប្អូនបង្កើតឪពុកអ៊ុំខ្ពស់ៗទាំងអស់។

កៈ ហើចុះម្ដាយវិញអ៊ុំគិតថាគាត់ជាមនុស្សបែបណា?

ខ៖ បើអ៊ុំពៅគេហើយអ៊ុំដឹងមកគាត់ចាស់ណាស់ទៅហើយឃើញតែគាត់ធ្វើសមាធិកម្មដ្ឋានគាត់ធ្វើតែកម្មដ្ឋានហ្នឹង គាត់ទៅតែបំពេញធម៌អត់ដែលឃើញគាត់រកអីផងអ៊ុំដឹងក្តីមកអត់ដែលឃើញគាត់រកអីសោះឃើញតែគាត់ទៅវត្តហើយគាត់ធ្វើខាងធ្មបពីដើមគាត់ធ្វើធ្មបគាត់អត់មានរកអីទេហើយដាច់ប៉ុលពតមកជំនាន់៧៩អ៊ុំមកនៅក្រោយអូសស្កូនេះក្រោយ៧មករានេះផ្ទះអ៊ុំនៅក្រោយ៧មករានេះអ៊ុំឃ្វាលតែម្តាយរបស់អ៊ុំដេញចាប់មួយថ្ងៃៗសឹងតែមិនបានធ្វើអីទេ ហ្នឹងចែម៉ាចអីដេញតែចាប់ជីដូនបើប្តីគាត់មួយអត់មានឆ្អឹងកាន់ទេកូនគាត់បួនទាំងកូនប្រសារប្រាំបីចៅជប់ប្រាំមួយទៀតទាំងអស់ម្តែប្រាំអត់មានឆ្អឹងកាន់ទេហើយដល់ពេលដាច់ប៉ុលពតមកគាត់ទៅជាវង្វេងដើរតែឃំដើរតែស្រែកហើយកូនដេញចាប់គាត់វង្វេងទៅអញ្ចឹងទៅណាស់។

ក៖ ចាស!

ខ៖ អញ្ចឹងអ៊ុំដើរឃ្វាលម្តាយទឹកភ្នែករហូតទាល់តែគាត់ស្លាប់ៗនៅឆ្នាំ៩៧ កំសត់ណាស់អ៊ុំដើរតួកំសត់មែនទែនអញ្ចឹងបានពេលសម្តាសអ៊ុំហ្នឹងអ៊ុំទប់ខ្លះបើតាមតែសាច់រឿងអ៊ុំជួបកំសត់ណាស់មួយជីវិតអ៊ុំៗអត់ដែលចង់បានទ្រព្យសម្បិត្តិអីទេអ៊ុំជាតិណាៗសុំកុំឱ្យវេទនាដូចជាតិនេះបើមានជាតិមុខជាតិក្រោយមែនសុំកុំឱ្យខ្ញុំវេទនាព្រាត់ឪពុកព្រាត់ម្តាយ បងប្អូនទាំង

ស្រស់ៗ។

ក៖ ហើយចង់សួរអ៊ុំៗធ្លាប់មានរឿងអ្វីចងចាំឬក៏មានអនុស្សាវរីយអីជាមួយឪពុកម្តាយដែលអ៊ុំចងចាំហាអ៊ុំ?

ខ៖ រឿងឪពុកម្តាយដែលបែកគ្នាដែលគេចាប់ឪពុកទៅអ៊ុំកំសត់ដើរជាមួយម្តាយដើរកាត់វាលកាត់ព្រៃហ្នឹងរហូតមកដល់ជំនាន់ប៉ុលពតគេយកបងៗទៅសម្លាប់ទៀតហើយអ៊ុំនៅតែពីរនាក់ម៉ែកូនហើយម្តាយចាស់អាយុចិតសិបជាងប៉ែតសិបហើយហ្នឹងចាស់មែនទែនហើយអ៊ុំនៅតូចមួយអ៊ុំអាយុមិនទាន់បាន១៨ឆ្នាំផង ពេលទៅធ្វើការជាមួយគេហើយពេលត្រលប់មកវិញអ៊ុំទៅជីកដំឡូងទៅឃ្វាលគោផងទៅជីកដំឡូងយកមកស្ងោរបើបានបួនប្រាំដុំទៅយកមកទុកឱ្យ

ម្តាយពិសារបីដុំទៅខ្លួងឯងហូបតែពីដុំទេកុំឱ្យច្រើនពេកព្រោះម្តាយខ្វិនឈឺហើយដើរអត់រួចទៀតខ្វិននៅលើផ្ទះទៀតកាលជំនាន់ប៉ុលពតម្តាយអ៊ុំខ្វិននៅលើផ្ទះរហូតទាល់តែដាច់ប៉ុលពតហើយអ៊ុំទៅទិញខ្លាញ់គោយកមកស្ងោរឱ្យគាត់ពិសារហើយយកខ្លាញ់ៗលាបក្បាលជង្គង់គាត់ហើយគាត់ដើររួចរហូតទៅណាស់។

ក៖ ហើយអញ្ចឹងអ៊ុំស្គាល់ឈ្មោះជីដូនជីតារបស់អ៊ុំអត់តាហើយនឹងយាយហាស?

ខ៖ អ៊ុំស្គាល់តា។

ក៖ អញ្ចឹងតាគាត់ឈ្មោះអីដែលអ៊ុំ?

ខ៖ តាខាងឪពុកឈ្មោះខូនហើយយាយរបស់អ៊ុំឈ្មោះផែង ខូន ផែងហើយខាងម្ដាយតាឈ្មោះម៉ូវយាយឈ្មោះល័ក្ខ ម៉ូវ ល័ក្ខ។

ក៖ ហើយចុះអ៊ុំមានដឹងគាត់កើតឆ្នាំណាអីអត់អ៊ុំ?

ខ៖ អ៊ុំអត់ដឹងអ៊ុំកើតអត់ទាន់ផងបើគិតជាអាយុគាត់បើតាខាងឪពុកអ៊ុំបើគិតជាអាយុគាត់ពីររយហាសិបឆ្នាំបាត់ហើយហ្នឹងអ៊ុំធ្វើម៉េចកើតទាន់បើបងទី៣ទី៤គេកើតមិនទាន់ផងគេអាយុ៧០ហើយចុះអ៊ុំទៀតអ៊ុំកើតមិនទាន់ទេ។

ក៖ ហើយចុះមានដឹងអ្វីខ្លះពីជីដូនជីតារបស់អ៊ុំដែរអត់ធ្លាប់មានលឺរឿងគាត់ដែលអត់?

ខ៖ អ៊ុំដូចអត់ដែលលឺអីទេព្រោះមនុស្សជំនាន់ដើមដូចជីតាអ៊ុំអីសុទ្ធតែមនុស្សជំនាន់ជ័យវរ្ម័នមិនធម្មតាទេគាត់ ខ្ពស់ៗហាធំៗហាតារបស់អ៊ុំសុទ្ធតែ២ម៉ែត្រ មួយម៉ែត្រកៅអី។

ក៖ អូ...ខ្ពស់ហា។

ខ៖ ខ្ពស់ៗហាសដល់ពេលមកដល់អ៊ុំនេះវាដាច់ពីគាត់បាត់ហើយប្រាប់គេក៏គេអត់ជឿដែរ។

ក៖ អញ្ចឹងអឺ...អ៊ុំមានសាច់ញាតិទៅរស់នៅក្រៅប្រទេសអីដែរអត់អ៊ុំ?

ខ៖ អ៊ុំមានរស់នៅអាមេរិកនៅកាលីហ្វ័រញ៉ា នៅឡូសអែនជេឡែស។

ក៖ ត្រូវជាអីដែរអ៊ុំ?

ខ៖ ត្រូវជាជីដូនមួយបង្កើតហ្នឹងអ៊ុំហើយគាត់មានតែម្នាក់ឯងគត់ ប្អូនរបស់ម្ដាយអ៊ុំហ្នឹងកូនគាត់មួយនោះឈ្មោះស្រីហេងឈ្មោះកំណើតរបស់គាត់ឈ្មោះម៉ែន សិរី តែជំនាន់ប៉ុលពតហ្នឹងគាត់បានរត់ចេញពីប្រទេសកម្ពុជាទៅថៃគាត់រត់ទៅមួយកំប៉ាល់គេលិចស្លាប់ទាំងអស់រស់តែគាត់ម្នាក់ គាត់ឈ្មោះប៉ែន សិរីតែគាត់ប្រែឈ្មោះគាត់រាល់ថ្ងៃនៅអាមេរិកគាត់ដាក់សិរី ហេងវិញដោយសារគាត់ហេងដែលបានរស់អញ្ចឹងគាត់ដាក់សិរី ហេងរាល់ថ្ងៃហ្នឹង។

ក៖ ហើយអញ្ចឹងចង់សួរឈ្មោះប្តីអ៊ុំឈ្មោះគាត់ឈ្មោះអីអ៊ុំ?

ខ៖ ឈ្មោះអ៊ុល សាវ៉ាន។

ក៖ ហើយអ៊ុំមានចាំអត់ពេលអ៊ុំរៀបការនៅថ្ងៃខែឆ្នាំណាអ៊ុំ?

ខ៖ អើយ...ឆ្នាំទីប៉ុន្មានទេឆ្នាំវកដឹងតែឆ្នាំខ្មែរ។

ក៖ អត់ចាំឆ្នាំពេលអ៊ុំរៀបការអត់ចាំហោអ៊ុំ?

ខ៖ អត់ចាំ។

ក៖ អញ្ចឹង....

ខ៖ អ៊ុំរៀបការហ្នឹង១៩៧៩ អ៊ុំការនៅឆ្នាំ១៩៧៩តែរកនឹកខែមិនដឹងខែអីខែយើងខែពិសាខខែអី។

ក៖ ខ្ញុំអត់ដឹងដែល។

ខ៖ យើងឥឡូវនេះខែប៉ុន្មានខែ៨ហោស?

ក៖ ឥឡូវខែ៩។

ខ៖ ខែ៩អាស្រាពខែ១០ភទ្របុទខែ១១អស្សុជខែ១២កក្តិកខែធ្នូត្រូវហើកក្តិក។

ក៖ អត់អីទេអ៊ុំបើអត់ចាំខែក៏អត់អីដែលអ៊ុំ។

ខ៖ ខែ៤។

ក៖ ខែ៤?

ខ៖ អឺ...ខែចូលឆ្នាំត្រូវហើខែពិសាខ។

ក៖ ហើយពេលអ៊ុំរៀបការហ្នឹងឪពុកម្តាយអ្នករៀបចំឱ្យឬក៏អ៊ុំរៀបការដោយស្រឡាញ់ខ្លួនឯង?

ខ៖ អូ...អត់ទេអ៊ុំអត់ចេះស្រឡាញ់ទេម្តាយរបស់អ៊ុំទាំងខាងប្តីទាំងខាងអ៊ុំហ្នឹងដណ្តឹងមានស៊ីស្លាភ្ជាប់ពាក្យ កាលណុងនៅ១៩៧៩ហ្នឹងគេអត់មានការអីទេការបាយមួយឆ្នាំងៗដាំទៅហូបរួមទាំងអស់គ្នាទៅក្ងចដៃអីអញ្ចឹងទៅអត់មានទាំងភ្លេងផងកាលណុងតែការអ៊ុំត្រឹមត្រូវហោសដោយសារត្រឹមត្រូវជាងគេព្រោះអីបងប្អូនខាងប្តីអ៊ុំហ្នឹងគាត់ជាអាយ៉ៃៗស្មៀន ឈៀងហាស។

ក៖ ចាស!

ខ៖ អាយ៉ៃស្មៀន ឈៀងហ្នឹងហើយនឹងឪពុកមាររបស់អ៊ុំហ្នឹងគាត់ពួកម៉ាកគ្នាពីសង្គមចាស់

ឪពុកមារឈ្មោះស្មៀន សារឹមសួរប៉ារបស់ក្មួយក៏ស្គាល់ដែរ។

កៈ ចាស!

ខៈ ស្មៀន សារឹមហ្នឹងគាត់អ្នកចំរៀងលេខមួយប្រចាំខេត្តកំពង់ចាម អញ្ចឹងពួកម៉ាកគាត់អ្នកភ្លេងអញ្ចឹងដល់ពេលការអ៊ុំគាត់ទៅយកស្មៀន ឈៀងអីហ្នឹងមកលេងអាយ៉ៃចាប់ពីថ្ងៃការអ៊ុំហ្នឹងទៅអាយ៉ៃស្មៀនឈៀងកើតចាប់ទីការអ៊ុំហ្នឹងហ្មង។

កៈ ចាស!

ខៈ ការអ៊ុំហ្នឹងការដុរអង្ករទេមនិយាយទៅថ្លៃទឹកដោះដូរអង្ករទេ។

កៈ អញ្ចឹងថ្លៃបណ្ណាការដូរអង្ករ?

ខៈ ដូរអង្ករទេអង្ករ១០០គីឡូថ្លៃជាងគេហើយណាស់បងៗអ៊ុំ ជីដូនមួយៗអីគេការគេដូរអង្ករដែរតែ២០គីឡូអីទេថ្លៃទឹកដោះគេៗដូរ២០គីឡូ ៣០គីឡូទេអ៊ុំហ្នឹងថ្លៃជាងគេផ្អើលគេផ្អើលឯងហើយបាន១០០គីឡូអង្ករ។

កៈ ហើយដល់ពេលមុនអ៊ុំការមានដែលបានជួបអ៊ុំប្រុសអីដែលអត់?

ខៈ បើនៅស្រុកជាមួយគ្នាគាត់ទើបមកពីធ្វើទ័ពកាលជំនាន់ប៉ុលពតមកបានប្រហែលជាកន្លះខែការជាមួយអ៊ុំហ្មង។

កៈ អូ...

ខៈ តែគ្រាន់ថាស្គាល់គ្នាពីតូចៗអញ្ចឹងហាណាស់ដល់ពេលធំៗអត់ស្គាល់គ្នាស្រាប់ស្គាល់គ្នាថ្ងៃការហ្មង។

កៈ ហើយមួយទៀតចង់សួរអ៊ុំៗចេះភាសាអីខ្លះអ៊ុំ?

ខៈ អ៊ុំចេះតែខ្មែរទេ។

កៈ អញ្ចឹងអ៊ុំរៀនបានដល់ថ្នាក់ណាដែរអ៊ុំ?

ខៈ អ៊ុំរៀនកាលសង្គមអ៊ុំនៅតូចពេករៀនបានបីថ្នាក់រៀនត្រឹមថ្នាក់ទី១០ កាលណុងគេរាប់ពី១២ ១១ ១០ចេញពីថ្នាក់ទី១គឺគ្រូហើយសម័យដើមណុងនោះ។

កៈ ហើយអ៊ុំរៀននៅសាលាណាដែរ?

ខ៖ អ៊ុំរៀនសាលាដីដុះ។

ក៖ អូ...សាលាដីដុះ។

ខ៖ ហ្នឹងហើយ។

ក៖ ហើយចង់សួរមួយទៀតជីវិតអ៊ុំតាំងពីក្មេងរហូតមកដល់ឥឡូវអ៊ុំឃើញថាមានការផ្លាស់ប្តូរដែរអ៊ុំ?

ខ៖ អារឿងផ្លាស់វាចេះតែផ្លាស់ហើយក្មួយបើយើងពីមុនយើងជាកូនក្មេងដល់ឥឡូវយើងជាម្តាយគេឥឡូវយើងជាជីដូនគេទៀតអញ្ចឹងវាកាន់តែផ្លាស់ធ្ងន់ជាងមុនទៀតការគិតការគ្រប់គ្រងនៅក្នុងក្រុមគ្រួសារយើងធ្វើយ៉ាងម៉េចកុំឱ្យកូនប៉ះទង្គិចគ្នាយើងត្រូវធ្វើយ៉ាងម៉េចផ្តល់ជាអាហារតាំងពីដើមមកដើម្បីកូនយើងឱ្យបានមានសុភមង្គលមានតម្រិះវិជ្ជាហើយដាស់តឿនវាត្រូវរកស៊ីនេះៗដើម្បីចិញ្ចឹមជីវិតអញ្ចឹងយើងជាម្តាយគេយើងជាជីដូនគេយើងត្រូវទទួលខុសត្រូវសព្វបែបយ៉ាងទាំងអស់ អញ្ចឹងយើងត្រូវធ្វើយ៉ាងម៉េចណែនាំកូនពន្យល់កូនឱ្យដើរផ្លូវដែលល្អផ្លូវដែលសុចរិត។

ក៖ ហើយអញ្ចឹងអ៊ុំចូលចិត្តច្រៀងចូលចិត្តរាំអីដែលអត់?

ខ៖ ហេ...ពីមុនមកដាច់ប៉ុលពតហ្នឹងរាំណាស់ដែលហ្នឹងបើមិនឃាត់រាំចង់របូតខោហើយរាំអត់មានស្គរទេជំនាន់នោះវ៉ៃធុងទេណាស់។

ក៖ ចាស!

ខ៖ អត់មានស្គរដូចសម័យនេះទេ។

ក៖ ហើយអ៊ុំមានចេះលេងឧបករណ៍ភ្លេងអីអត់?

ខ៖ អ៊ុំអត់មានចេះទេ។

ក៖ ហើយអឺ...កាលអ៊ុំនៅតូចហាសផ្ទះអ៊ុំមានលក្ខណៈម៉េចដែលអ៊ុំ?

ខ៖ ពិបាកហាសកាលពីអ៊ុំនៅតូចបើផ្ទះអ៊ុំមានច្រើនកន្លែងដែលហ្នឹង ផ្ទះនៅស្រុកឯជើងព្រៃហ្នឹងផ្ទះអ៊ុំតូចប្រហែលជាពីមុខប្រាំម៉ែត្រទៅក្រោយប្រហែល៧ម៉ែត្រទេតែគ្រាន់ផ្ទះនៅកំពង់ចាមនោះផ្សេងផ្ទះនៅភ្នំពេញនោះផ្សេង។

កៈ ហើយអឺ...ចង់សួរមួយទៀតអ៊ុំរាល់ថ្ងៃកាន់សាសនាអីអ៊ុំ?

ខៈ អ៊ុំកាន់សាសនាគ្រិស្ដ។

កៈ អញ្ជឹងអឺ...ពេលក្រោយពីអ៊ុំបានជឿមកជីវិតអ៊ុំមានការផ្លាស់ប្ដូរអីខ្លះអ៊ុំ?

ខៈ ផ្លាស់ប្ដូរថាមានពរជ័យទ្រង់បានផ្ដល់ឱ្យអ៊ុំមានសិរីសួស្ដីហើយអ៊ុំមិនដែលគិតអ្វីទេឥឡូវតាំងពីមានព្រះជាបង្អែកមកគឺអ៊ុំពឹងតែលើព្រះគឺអ៊ុំអត់មានពឹងអ្វីក្រៅពីព្រះទេបើសិនជាអ៊ុំចង់បានអីមួយបើសិនជាទ្រង់ផ្ដល់ឱ្យនឹងមានពរជ័យបើសិនជាទ្រង់មិនផ្ដល់ឱ្យអ៊ុំឃើញតែអត់ៗបានអ៊ុំសង្ឃឹមទៅលើទ្រង់អ្នករៀបផ្លូវឱ្យអ៊ុំ។

កៈ ហើយអញ្ជឹងចង់ឱ្យអ៊ុំប្រាប់ពីពេលដែលលំបាកបំផុតក្នុងជីវិតអ៊ុំហាស?

ខៈ លំបាកមានតែជំនាន់ប៉ុលពតហ្នឹងហើយដែលលំបាកខ្លាំងបំផុតអ៊ុំព្រាត់ប្រាសបងប្អូនព្រាត់ប្រាសឪពុកជាទីស្រឡាញ់ដេកលើទ្រូងគាត់ហើយគេយកប្រឡេះទុកកូនដោយខ្លួនឪពុកដោយខ្លួនទៀតគេយកឪពុកទៅបាត់រហូតទាល់រាល់ថ្ងៃហ្នឹងដែលសោកសង្រេងជាងគេគឺឪពុកហ្នឹងហ្មង ម្ដាយអ៊ុំគាត់ស្លាប់ក៏ពិតមែនតែស្លាប់ដោយគាត់ឈឺនេះឪពុកនឹងកូនដេកឱបគ្នាគេបេះយកឪពុកទៅបាត់ហើយកូនយំស្រែករកឪពុករកដោយមិនដឹងរហូតទល់សព្វថ្ងៃហ្នឹង។

កៈ ហើយអញ្ជឹងពេលក្នុងជីវិតរបស់អ៊ុំតើអ៊ុំគិតថាពេលណាដែលសប្បាយបំផុតហាអ៊ុំ?

ខៈ បើក្នុងខ្លួនអ៊ុំអារម្មណអ៊ុំអត់ដែលសប្បាយផងចេះតែនឹកឃើញប្រវត្តិដើមជូរចត់មកអ៊ុំមិនដែលសប្បាយដូចគេទេ។

កៈ អញ្ជឹងបន្តទៀតអ៊ុំអញ្ជឹងចង់សួរអ៊ុំឆ្លងកាត់សម័យកាលណាខ្លះអ៊ុំ?

ខៈ អ៊ុំមានតែសម័យកាលមុនប៉ុលពតៗហ្នឹងកាលហ្នឹងទាហ៊ានហ្នឹងប៉ុលពត់ហើយមុនហ្នឹងទៀតទាហ៊ានមិនមែនជាប៉ុលពតទេជាខ្មែរសមុនប៉ុលពតទៀតរួចមកបានគេរ៉ែពួកទាហ៊ានហ្នឹងដាច់ទៅបានមានប៉ុលពត។

កៈ ចាស!

ខៈ រួចពីប៉ុលពតហ្នឹងមកវាមួយជំនាន់ហើយណាស់រ៉ែដាច់ទាហ៊ានទៅមួយជំនាន់ដល់ពេលដាច់ទាហ៊ានហ្នឹងចូលប៉ុលពតត្រូវមួយជំនាន់ទៀត ដល់មក៧៩នេះវាដាច់ប៉ុលពតទៀតឡើងបីជំនាន់។

កៈ កាលនៅពីក្មេងចង់សួរដែលអ៊ុំមានស្រម៉ៃចង់ក្លាយជាអីអត់អ៊ុំ?

ខ៖ ចេះតែស្រម៉ៃហើយកាលពីដើមស្រម៉ៃថាឪពុកអ៊ុំគាត់ចេះតែថាមីស្រីតូចកូនឯងអនាគតកូនឯងចង់ធ្វើអីពុកស្រឡាញ់កូនឯងចង់ឱ្យកូនឯងរៀនឱ្យអស់ថ្នាក់ហើយកូនឯងបានធ្វើជាសាស្រ្តចារ្យតែអ៊ុំរឿងហ្នឹងបានគ្រាន់តែនិយាយឱ្យគេលឺហ្នឹងចង់ខ្មាស់គេផងព្រោះវាអត់ជោគជ័យហើយក៏ពុកថាបើសិនជាពុកនៅពុកឱ្យកូនឯងរៀនពុកអត់ឱ្យកូនឯងការទេតែបើពុកអត់នៅប្រហែលជាម៉ែបង្ខំឱ្យកូនឯងការហើយបើពុកនៅពុកឱ្យកូនឯងរៀនហើយអឺ...អ៊ុំស្រឡាញ់ខាងវិជ្ជាខាងអក្សរសាស្រ្តហ្នឹងអ៊ុំស្រឡាញ់មែនទែនអ៊ុំរៀនកាលណុងអ៊ុំនៅតូចគេអត់ឱ្យចូលរៀនទេជំនាន់ដើមប្រាំឆ្នាំគេអត់ឱ្យចូលទេណាស់គេឱ្យដាក់ដៃលើក្បាលទាល់តែដល់ស្លឹកត្រចៀកបានគេឱ្យចូលហើយអ៊ុំយំហាសទៅរៀនហ្នឹងអ៊ុំយំទៅបានគេឃើញអាណិតអ៊ុំកូនកំព្រាអញ្ចឹងក៏

បងៗហ្នឹងក៏យកទៅផ្ញើគ្រូនៅសាលាបឹងស្នាយនេះអាជិតមាត់បឹងនេះសាលាហ្នឹងវាសាលាជនបទហាសអញ្ចឹងយកទៅដាក់នៅហ្នឹងវាអត់មានឡានម៉ូតូអីគេឱបយកទៅដាក់ទៅអ៊ុំចូលរៀនអ៊ុំរៀនថ្នាក់ទី១២ ពីដើមគេរៀនពីលើចុះក្រោមហាសអ៊ុំរៀនថ្នាក់ទី១២ហ្នឹងចូលទៅគេរៀនពាក់កណ្ដាលឆ្នាំហើយអ៊ុំទៅរៀនជាមួយគេអ៊ុំប្រឡងជាប់ទៅអ៊ុំជាប់ចូលថ្នាក់ទី១១ ជាប់ថ្នាក់ទី១១ហ្នឹងដល់រៀនទៅគ្រូថាឯងរៀនពូកែឯងទៅរៀននៅជីដុះវិញទៅអត់កើតទេឯងនៅរៀនជាមួយសិស្សនៅហ្នឹងអត់បានទេព្រោះឯងតូចក៏ពិតមែនតែគ្រូគ្រាន់ឱ្យឯងនៅមើលឱ្យស៊ាំនឹងគេការពិតឯងធ្វើត្រូវទាំងអស់អញ្ចឹងលោកគ្រូបញ្ជូនអ៊ុំឱ្យទៅរៀននៅជីដុះ អ៊ុំកាលណុងចូលពាក់កណ្ដាលមែនតែអ៊ុំរៀនបានលេខមួយរហូតហើយអ៊ុំតូចពីបាកសរសេរៗល្មមតែបាន។

ក៖ ហើយមួយទៀតអ៊ុំមានបទពិសោធនអីខ្លះចង់ចែកចាយដល់កូនចៅហាសអ៊ុំ?

ខ៖ បទពិសោធនអីអូនបើយើងវាជួរចត់អញ្ចឹងបើគេសម័យឥឡូវហ្នឹងគេទូលំទូលាយជាងយើងគិតម៉េច ឥឡូវកូនគេរៀនថ្នាក់ធំជាងយើងៗរៀនបានតែបីថ្នាក់ហ្នឹង។

ក៖ ចាស!

ខ៖ សូម្បីកូនឯងរៀនថ្នាក់ទី១២បាត់ហើយដឹង។

ក៖ ខ្ញុំចប់ឆ្នាំទី៤ទៀតហើយ។

ខ៖ ហូ...ចប់ឆ្នាំទ៤ហើយបើអ៊ុំរៀនបាន៣ថ្នាក់ធ្វើម៉េចទៅៗបង្រៀនគេម៉េចកើត។

ក៖ ដោយសារក្រៃលោអ៊ុំធ្លាប់ឆ្លងកាត់ជីវិតបានច្រើនអញ្ចឹងមានបទពិសោធនច្រើនចង់ចែករំលែកកូនចៅហាសអ៊ុំ។

ខ៖ អើ...បទពិសោធនវាចេះតែមានហើយដូចថាយើងចេះអត់ធ្មត់ចេះតស៊ូនៅឆាកជីវិតរបស់យើងទោះបីលំបាកយ៉ាងណាក៏ស៊ូទ្រាំទៅ។

ក៖ ចាស!

ខ៖ ទ្រាំទាល់តែជោគជ័យឥឡូវហ្នឹងបានជោគជ័យវិញហើយដោយសារតែអ៊ុំមានផ្ទះហើយឥឡូវអ៊ុំរទេ្រតហើយកាលមុនអ៊ុំមានប្រាក់ខែវាអាចចិញ្ចឹងកូនរស់ដែលណាស់ដល់ឥឡូវហ្នឹងយើងអត់ទេយើងអត់មានធ្វើអីទេឥឡូវហ្នឹងយកមើលចៅយកតែបាយហូបតាមកូនវិញទេឥឡូវហ្នឹង។

ក៖ ហើយអញ្ចឹងអឺ...ជាចុងក្រោយអ៊ុំមានពាក្យអីចង់ផ្តាំផ្ញើទៅកូនចៅជំនាន់ក្រោយទៀតហាសអ៊ុំ?

ខ៖ គ្មានពាក្យអីទេអ៊ុំមានតែពាក្យថាចូរកូនៗសារក្រោយត្រូវចេះតស៊ូក្នុងឆាកជីវិតហើយនឹងតស៊ូជាមួយនឹងព្រះព្រោះអីអ៊ុំបានដើរតាមផ្លូវរបស់ព្រះជោគជ័យហើយទ្រង់ផ្តល់ឱ្យអញ្ចឹងទ្រព្យសម្បត្តិជារបស់ក្រៅខ្លួនទេអញ្ចឹងយើងមានតែសេចក្តីជំនឿទៅលើទ្រង់ហ្នឹងហើយដែលទ្រង់រៀបផ្លូវឱ្យយើងនោះ។

ក៖ ហើយអញ្ចឹងជាចុងក្រោយសូមអរគុណអ៊ុំដែលបានឱ្យខ្ញុំមកសម្ភាសថ្ងៃហ្នឹងហើយចង់សួរមួយសំណួរទៀតអញ្ចឹងអ៊ុំអឺ...អនុញ្ញាតឱ្យខ្ញុំយកសម្លេងហើយនឹងរូបថតរបស់អ៊ុំទៅដាក់នៅលើគេហទំព័ររបស់សកលវិទ្យាល័យព្រីកហាំយ៉ាំងដែរឬទេអ៊ុំ?

ខ៖ អ៊ុំមិនថាអីទេប៉ុន្តែគ្រាន់ថាធ្វើម៉េចកុំឱ្យប៉ះពាររដ្ឋាភិបាលព្រោះអីយើងអត់មានអីត្រូវប៉ះពារជាមួយគេ។

ក៖ អញ្ចឹងអត់អីទេអរគុណច្រើនអ៊ុំ៕